# សមភាព និង សមធម៌យេនឌ័រ

# ឈំហាត់សន្តិភាព

- សំនួរ:
- ការងារថែរក្សាផ្ទះ ដូចជាបោសសំអាត ដាំបាយ បោកខោអាវ តើភាគច្រើនបុរសជាអ្នកធ្វើ រឺ ស្ត្រី?
- ពេលមានសមាជិកគ្រួសារឈឺ តើភាគច្រើនបុរស រឺ នារីដែលជាអ្នកថែទាំអ្នកជំងឺ?
- ការពុះអុស ដងទឹក ការចូលរួមក្នុងការប្រជុំផ្សេងៗក្នុងភូមិ តើភាគច្រើនបុរស រឺ ស្ត្រីជាអ្នកធ្វើ និង ចូលប្រជុំ?
- ងូតទឹកអោយកូន ថែទាំជម្ងឺកូន បញ្ចុកបាយកូន ដាក់បាយជ្រូក ទៅផ្សារទិញម្ហូប តើភាគច្រើន បុរស រឺ នារីជាអ្នកធ្វើ?

# ឈំហាត់ចប់បញ្ចាញ

- បុរស និង ស្ត្រីមានសិទ្ធិស្មើគ្នា ក្នុងការដើរប្រណាំងទៅកាន់គោលដៅ ចុះហេតុអ្វីបានជាក្រុមស្ត្រីដើរមិនទាន់ក្រុមបុរស? ព្រោះក្រុមស្ត្រីមានកាន់កៅអីច្រើន។ ត្រង់នេះហើយដែលចង់បញ្ជាក់ថាស្ត្រីមិនអាចធ្វើការសង្គមបានច្រើនឿនលឿននោះទេពីព្រោះស្ត្រីមានបន្ទុកការងារក្នុងគ្រួសារច្រើន ដូចជាការថែទាំកូនចៅ ផ្ទះសម្បែង និយាយរួមរាប់រងក្នុងគ្រួសារទាំងមូល ហេតុនេះហើយបើគ្មានសមធម៌ពីបុរសទេ ស្ត្រីក៏ពិបាកចូលរួមក្នុងការអភិវឌ្ឍន៍ដែរ។

# សមភាព និង សមធម៌

- សមភាព: សំដៅលើភាពស្មើគ្នាចំពោះតួនាទីក្នុងសង្គម
- សមធម៌: គឺការយោគយល់ទៅតាមស្ថានភាពពិសេសរបស់គ្នាទៅវិញទៅមក។

# សមភាពយេនឌ័រ

គឺជាការទទួលបានពិតប្រាកដនូវផលប្រយោជន៍ ឱកាស សិទ្ធិ អំណាចគ្រប់គ្រង តំណែង ឋានៈ តួនាទីតំលៃ កិត្តិយស ឯករាជ្យភាពដូចៗគ្នារវាងបុរសនិងស្ត្រី ទោះបីក្នុងគ្រួសារ ការិយាល័យ និងគ្រប់ទីសាធារណៈទាំងអស់។

ឧទាហរណ៍ ៖

- ក្មេងប្រុស និងក្មេងស្រីមានសិទ្ធិទៅសាលារៀនដូចៗគ្នា

- បុគ្គលិកប្រុស និងស្រីទទួលបានប្រាក់ខែស្មើគ្នាក្នុងតួនាទីដូចគ្នា

- កូនប្រុស កូនស្រីត្រូវទទួលកេរមរតកស្មើៗគ្នាពីឪពុកម្តាយ

- ពលរដ្ឋទាំងប្រុស ស្រីមានសិទ្ធិទៅបោះឆ្នោតសំរាប់ការបោះឆ្នោតដូចគ្នា

# សមធម៌យេនឌ័រ

សំដៅទៅលើភាពចាំបាច់ដែលបុរស និងស្ត្រីត្រូវការសំរាប់ ការរស់នៅរបស់គេប្រចាំថ្ងៃ។ យើងធ្វើអ្វីៗដើម្បីអោយមានសមធម៌រវាងបុរស និងស្ត្រីនៅគ្រប់ទីកន្លែង និងពេលវេលា។ បើយើងនិយាយផលប្រយោជន៍នៅក្នុងសមធម៌យេនឌ័រ មានន័យថា ជាការលែលកផលប្រយោជន៍នោះ អោយទទួលបានឱកាស ធនធានដូចៗគ្នា តែត្រូវចេះយោគយល់គ្នា អោយតំលៃគ្នា មិនប្រកាន់តួនាទី ជាពិសេសយើងផ្តល់ឱកាសអោយអ្នកទន់ខ្សោយ ឬ ចំពោះអ្នកដែលទទួលការរើសអើងក្នុងសង្គម។ វាជាយុទ្ធសាស្រ្តមួយដើម្បីយកជ័យជនះចំពោះការលំអៀងតាមរបៀបការអនុគ្រោះដើម្បីអោយមានសមភាព មានន័យថាការទទួលបានដូចៗគ្នា។

# ឧទាហរណ៍ ៖

- ដើម្បីអោយកុមារីចូលសាលារៀនអោយបានច្រើននាក់សាលាមានគោលនយោបាយមួយគឺ បច្ចុះតំលៃសំរាប់ក្មេងស្រី ជាពិសេសក្មេងស្រីចេញពីគ្រួសារក្រីក្រ។

- ប្រសិនលទ្ធផលប្រលងអ្វីមួយដែលបុរស និងស្ត្រីបានពិន្ទុស្មើគ្នានោះយើងផ្តល់អទិភាពដល់នារី។

- ពេលធ្វើការជ្រើសរើសការងារត្រូវកំណត់យកចំនួននារី និងបុរសអោយស្មើគ្នា (ផ្តល់ឱកាសដល់នារី បើមិនអញ្ចឹងទេនារីមានភាពលំបាកក្នុងការប្រណាំងប្រជែង)។

# សូមអរគុណ